**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា**
**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**
ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP- IDA
KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្តីប្រកាសព័ត៌មាន

- “ *តើយើងអាចរស់នៅដោយគ្មានដីធ្លីរបស់យើងយ៉ាងដូចម្តេច? បើសិនបាត់បង់ដី ខ្ញុំមិនអាចរស់នៅបានទេ។* ”
  លោក **បាន យ៉ី** អាយុ ៥០ឆ្នាំ នៅឃុំជីក្រែង ខេត្តសៀមរាប។
- “ *ខ្ញុំមិនខឹងនឹងក្រុមហ៊ុនទេ។ អ្វីដែលខ្ញុំខឹងគឺប្រព័ន្ធច្បាប់ រដ្ឋាភិបាល សាលាក្រុង រួមទាំងអាជ្ញាធរ និង ប៉ូលីស។* ”
  លោក **ចាន់ វិចិត្រ** នៅសហគមន៍ដីក្រហម ក្រុងភ្នំពេញ។
- “ *ទាហាន និងប៉ូលីសមានកាំភ្លើង គឺដើម្បីការពារប្រជាជន មិនមែនដើម្បីបាញ់គេនោះទេ។* ”
  ព្រះតេជគុណ **លួន សុវ៉ាត** (ដែលបងប្រុស និងក្មួយរបស់ព្រះតេជគុណស្លាប់ ដោយសារការបាញ់ប្រហារ កាលពីថ្ងៃទី២២ ខែមីនា នៅស្រុកជីក្រែង ខេត្តសៀមរាប។)
- “ *យើងនៅតែភ័យរន្ធត់។ យើងនៅតែមានអារម្មណ៍ឈឺ។ យើងមិនអាចគេងបានទេ។* ”
  លោកស្រី **សឿន សារុន**, រយៈពេល២ឆ្នាំក្រោយពីការបណ្តេញដោយហឹង្សានៅភូមិស្ពានឆេះ ក្រុងព្រះសីហនុ។

---

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្ស (CHRAC) ដែលជាសម្ព័ន្ធ នៃសមាគម អង្គការមិនមែនរដ្ឋាភិបាលចំនួន២១ សូមស្វាគមន៍ចំពោះគំរោងអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល។ ប៉ុន្តែគំរោងអភិវឌ្ឍន៍ទាំងនោះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ជីវិត និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទេ។ វាគួរតែជាកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រប្រកបដោយសមធម៌ និង មិនមែនបំរើឱ្យតែជាប្រយោជន៍ក្រុមហ៊ុនឯកជន និងអ្នកមានអំណាចនោះទេ។ សហគមន៍របស់យើងកំពុងតែបាត់បង់ដីធ្លី និងធនធានធម្មជាតិ។ ទាំងនោះ គឺជាធនធានដែលប្រជាពលរដ្ឋយើងពឹងពាក់អាស្រ័យអស់ជាច្រើនទសវត្សមកហើយ។

ម្ចាស់ជំនួយ និងសហគមន៍អន្តរជាតិ ផ្តល់ជំនួយរាប់រយលានដុល្លារសហរដ្ឋអាមេរិកជារៀងរាល់ឆ្នាំ ដើម្បីជួយអភិវឌ្ឍន៍ប្រទេសកម្ពុជា ជាពិសេស គឺដើម្បីជួយកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសនេះ។ ម្ចាស់ជំនួយបាននិយាយថា ពួកគេផ្តល់ថវិកាទាំងនេះ គឺដើម្បីកសាងលទ្ធិប្រជាធិបតេយ្យ កាត់បន្ថយភាពក្រីក្រ ការពារធនធាន

ធម្មជាតិ លើកស្ទួយសុខភាព និងសុខមាលភាព និងសេវាអប់រំ ជាដើម។ល។ តែទោះបីជាយ៉ាងនេះក៏ដោយ យើងនៅតែសង្កេតឃើញថា ប្រជាជនក្រីក្រកំពុងកាន់តែក្រីក្រទៅៗ និង អ្នកមានកំពុងកាន់តែមានទៅៗ។

ប្រជាជនកម្ពុជាសាមញ្ញ ដែលបានរងផលប៉ះពាល់ដោយសារតែ "គំរោងអភិវឌ្ឍន៍ផ្សេងៗ" កំពុងតែឆ្ងល់ថាតើជំនួយអភិវឌ្ឍន៍ផ្សេងៗទាំងនោះ ត្រូវបានរាជរដ្ឋាភិបាលរបស់ខ្លួនប្រើប្រាស់ដោយរបៀបណា។ បន្ថែមលើសពីនេះទៅទៀត ពួកគេមើលឃើញថា ដីធ្លីជាច្រើនកំពុងត្រូវបានផ្តល់សម្បទានទៅឱ្យក្រុមហ៊ុនឯកជន ឬសំរាប់បំរើជាប្រយោជន៍ហិរញ្ញវត្ថុឯកជនទៅវិញ។ ហើយទីបំផុត ជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាទាំងនោះកំពុងរងផលប៉ះពាល់ជាខ្លាំង។

ប្រជាពលរដ្ឋទូទាំងប្រទេស បានធ្វើការកត់សំគាល់និន្នាការបច្ចុប្បន្នមួយចំនួន ខាងក្រោមនេះ

- ការកើនឡើងនូវការដកហូតធនធានធម្មជាតិ
- ការកើនឡើងនូវអំពើហឹង្សាប្រឆាំងប្រជាសហគមន៍
- ការកើនឡើងនូវការប្រើកំលាំងយោធាបំពារបំពានទៅលើប្រជាពលរដ្ឋកុំឱ្យធ្វើការតវ៉ាការពារសិទ្ធិមនុស្ស
- ការកើនឡើងនូវការបំភិតបំភ័យដោយតុលាការ
- ការកើនឡើងនូវបញ្ហាដែលជាលទ្ធផលនៃការធ្វើសម្បទានដីធ្លី
- ការកើនឡើងនូវបញ្ហាដែលលទ្ធផលនៃការធ្វើសម្បទានរ៉ែ
- ការកើនឡើននូវបញ្ហាដែលលទ្ធផលនៃការធ្វើសម្បទានទេសចរណ៍
- ការកើនឡើងនូវបញ្ហាដែលលទ្ធផលនៃការធ្វើទំនប់វ៉ារីអគ្គីសនី

ក្នុងរបាយការណ៍ ស្តីពី "*ការកំពុងបាត់បង់ដីៈ ការបណ្តេញចេញដោយបង្ខំ និងការបំភិតបំភ័យក្នុងប្រទេសកម្ពុជា*" គឺជាកំរងឯកសារនៃព្រឹត្តិការណ៍ដែលបានកើតឡើងរួចទៅហើយទាក់ទិននឹងបញ្ហាដីធ្លី និងការដកស្រង់សំដីរបស់ប្រជាពលរដ្ឋដែលរងគ្រោះ។

សំលេងក្នុងរបាយការណ៍ ជារបស់សំលេង (សំដី) ប្រជាជនកម្ពុជាដែលជាអ្នកត្រូវបាន ឬកំពុងប្រឈមមុខនឹងការបណ្តេញចេញ។ ប្រជាពលរដ្ឋភាគច្រើនបានទទូចសុំឱ្យដាក់ឈ្មោះ និងរូបថតរបស់ពួកគេ ដោយគេជឿជាក់ថា ភាពបើកចំហរបែបនេះ នឹងអាចនាំឱ្យមានយុត្តិធម៌ និងដំណោះស្រាយសមរម្យដល់ពួកគេ។

ការជឿជាក់បែបនេះកំពុងផុសចេញឡើង។ យើងជឿជាក់ថា វាគឺជាស្ពានសំរាប់តំណាក់កាលបន្ទាប់នៃការធ្វើការឱ្យប្រសើរឡើងវិញរបស់ប្រទេសកម្ពុជាចេញពីវិវាទស៊ីវិលអស់ជាច្រើនទសវត្ស ដែលភាគច្រើនត្រូវបានបន្តយូរអង្វែង ឬ កាន់តែធ្ងន់ធ្ងរឡើង ដោយសារតែមានអំណាចបរទេសពាក់ព័ន្ធ។

ក្រោយពីបានស្តាប់សំលេងរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារការបាត់បង់ដីធ្លី និង ជីវភាពរបស់ពួកគេ យើងជាអង្គការសង្គមស៊ីវិលសូមស្នើសុំ ៤ ចំណុច ដើម្បីបង្ហាញពីស្ថានភាពរបស់អ្នកទាំងនោះ ដែលកំពុងប្រឈមមុខចំពោះការបាត់បង់ដីធ្លី និងជីវភាព ដូចខាងក្រោមៈ

១- អ្នកទាំងឡាយដែល (មាននៅក្នុងរបាយការណ៍) បានបង្ហាញថា ជំនឿរបស់គេក្នុងប្រព័ន្ធយុត្តិធម៌គួរតែធានាថា ពួកគេមានសុវត្ថិភាពពេញលេញក្នុងការធ្វើយ៉ាងដូចនេះ ។

២- ការអនុវត្តន៍ច្បាប់ភូមិបាលគួរពិនិត្យឡើងវិញ និងកែលំអឱ្យបានប្រសើរ ។

៣- តុលាការ អាជ្ញាធរ និង កំលាំងប្រដាប់អាវុធ គួរតែបំរើការពារប្រជាពលរដ្ឋ និងត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តខុសរបស់ខ្លួន និង

៤- ប្រជាជនកម្ពុជា គួរតែអាចចូលរួម និងទទួលផលប្រយោជន៍ឱ្យបានប្រសើរជាងនេះ នៅក្នុងការអភិវឌ្ឍន៍ប្រទេសរបស់យើង ។

យើងជឿជាក់ថា ការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជា គឺចាំបាច់សំរាប់តំណាក់កាលបន្ទាប់នៃការកសាងប្រទេសជាតិឡើងវិញ ។ យើងក៏មានជំនឿថា រាជរដ្ឋាភិបាលរបស់យើង ក៏ដូចជាប្រជាជនកម្ពុជា គឺកំពុងស្វែងរកមធ្យោបាយដើម្បីឈានដល់តំណាក់កាលទៅមុខទៀត ហើយដែលចំណុចចាប់ផ្តើមនោះ គឺការស្វែងរកការបែចែករំលែកដីធ្លីដ៏ត្រឹមត្រូវ តាមរយៈការសន្ទនាដោយគោរពគ្នាទៅវិញទៅមក ។

*ភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩*


***<u>សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង:</u>***

| | | |
|---|---|---|
| លោក **សុក សំអឿន** | ប្រធានសំរបសំរួលស្តីទី និងជានាយកអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោក **នី ចរិយា** | ប្រធានផ្នែកស៊ើបអង្កេតសមាគមអាដហុក | ទូរស័ព្ទលេខ: ០១១ ២៧៤ ៩៥៩ |